គណបក្ស សិទ្ធិមនុស្ស
HUMAN RIGHTS PARTY
បំរើ ការពារ កសាង


លេខ.០០២៧/១០.គ.ស.ម

ភ្នំពេញ, ថ្ងៃទី០៥ ខែមិនា ឆ្នាំ ២០១០

# សេចក្តីជូនដំណឹង

ក្នុងដំណើរបំពេញបេសកកម្មចុះជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋកាលពីថ្ងៃទី ៤ ទី ៥ ខែមិនា ឆ្នាំ ២០១០ តាមផ្លូវជាតិលេខ៥ ក្នុងទឹកដីខេត្តកំពង់ឆ្នាំង ខ្ញុំ **កឹម សុខា** ប្រធាន **គណបក្សសិទ្ធិមនុស្ស** បានឃើញស្លាក **គណបក្សប្រជាជនកម្ពុជា** នៅតាមដងផ្លូវដែលមានសរសេរឈ្មោះគណបក្សប្រជាជនកម្ពុជា និងរូបថតមេដឹកនាំគណបក្សប្រជាជនកម្ពុជា ទាំងបីរូប នៅពីលើបាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ** ។

ជាទូទៅគេធ្លាប់តែឃើញ **ព្រះរាជាណាចក្រកម្ពុជា** និង **ជាតិ សាសនា ព្រះមហាក្សត្រ** នៅពីលើ។ ខ្ញុំ **កឹម សុខា** ក្នុងនាមខ្លួនខ្ញុំផ្ទាល់ និងក្នុងនាមគណបក្សសិទ្ធិមនុស្ស យល់ឃើញថា **ជាតិត្រូវនៅផុតខ្ពស់ពីលើបក្ស មិនគួរធ្វើឱ្យមានការច្របូកច្របល់ ឬក៏ជាបំណង ជាតិជាបក្ស បក្សជាជាតិ ដូចរបបកុម្មុយនីស្តនោះទេ** ។

តើនេះជាចេតនា ឬអចេតនារបស់គណបក្សប្រជាជនកម្ពុជា ដែលដាក់ឈ្មោះបក្ស រូបថតមេដឹកនាំបក្សនៅពីលើបាវចនាជាតិ សាសនា ព្រះមហាក្សត្រនោះ ?

គណបក្ស សិទ្ធិមនុស្ស H.R.P. HUMAN RIGHTS PARTY

**សំរាប់ពតិមានបន្ថែម :**

សូមទាក់ទង ០១១ ៧៧៧ ៧៥០


Address: #72-74 Street 598, Sangkat Boeng Kok 2, Khan Tuol Kok, Phnom Penh, Cambodia.
Tel: (+855) 17 303 900 / 023 884 649 | Email: hrpcambodia@yahoo.com , Website. www.hrpcambodia.info